K03347
TSL BOX 4

## ករណី នុត លាស់ .

អាយុ ៤៣ ។ ប្រុស ។ ខ្មែរ ។ មានគ្រួសារ ។

- អតីតៈកម្មកររោងចក្រ កៅស៊ូកង់ឡាន តាខ្មៅ ។
- បច្ចុប្បន្នៈ កម្មករ "ក១" ។

១៩៧៣ . ចូលសេ អ៊ី អា នៅរោងចក្រកង់ឡានតាខ្មៅ

អ្នកនាំចូល និង អ្នកទទួលស្គាល់ ឈាង សាអ៊ីម - បច្ចុប្បន្ន មិនដឹង ។

ប្រាក់ខែ ៥ ប៉ឺនរៀល

បានរៀនវិជ្ជា សេ អ៊ី អា រយៈកន្លះខែ នៅក្នុងរោងចក្រ

ភារកិច្ច ឃោសនាប្រឆាំងបដិវត្ត និងពង្រីកកម្លាំងសេអ៊ីអា

ស៊ើបការណ៍រកបណ្តាញខ្មែរក្រហម ។

សកម្មភាព . ក្រោយ ១៧.៤.៧៥ :

ធ្វើសកម្មភាព សេអ៊ីអា ក្នុងក្រុម តែម សុផុន ។

បានឃោសនាបំផុសបំផុលប្រឆាំងបដិវត្ត ដូចជាថា អង្គការបដិវត្ត

ប្រើមនុស្សដូចសត្វ គ្មានពេលឈប់សំរាក បំបិតសិទ្ធិសេរីភាព

គ្រប់បែបយ៉ាង កម្មាភិបាលដឹកនាំ ចេះតែបញ្ជា មិនចេះអី ។

- បានធ្វើឱ្យខូចម៉ាស៊ីនតំឡើងកង់ឡាន អស់ ២ ដង ។
- បានធ្វើឱ្យខូចពុម្ពកង់ឡាន អស់ ៤ ។
- បានធ្វើឱ្យខូចម៉ូទ័របូមទឹក អស់ ៣ ។